# ស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា

## ជំពូក ១៦

# ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម

~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~


អគ្គលេខាធិការដ្ឋាន

អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពកម្ចាត់មីន និងសង្គ្រោះជនពិការដោយសារមីន

អគារថ្មីផ្លូវលេខ ២៧៣កែង៥១៦ សង្កាត់ទួលសង្កែ ខណ្ឌទួលគោក រាជធានីភ្នំពេញ

ទូរស័ព្ទលេខ: ០២៣-៨៨៥-៩៤១|០២៣-៨៨១-៤៩២

គេហទំព័រ: www.cmaa.gov.kh
~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~~

# មាតិកា


ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម ........ 2

សេចក្តីផ្តើម ........ 2

១. ទ្រង់ទ្រាយ វិសាលភាព ........ 3

៣. គោលការណ៍ទូទៅ ........ 3

៤. ការស្រាវជ្រាវមិនបច្ចេកទេស ........ 3

៥. ការស្រាវជ្រាវបច្ចេកទេស ........ 4

៦. ធនធាន និងវិធីសាស្ត្រ ........ 10

៧. ការកំណត់ទំហំ និងរបាយការណ៍ ........ 11

៨. ការទទួលខុសត្រូវនិងភាតព្វកិច្ច ........ 12

# ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម

## សេចក្តីផ្តើម

ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម គឺជាវិធីសាស្ត្ររួមបញ្ចូលគ្នារវាងការស្រាវជ្រាវមិនបច្ចេកទេស និង ការស្រាវជ្រាវបច្ចេកទេស ដែលត្រូវបានរៀបចំឡើងដើម្បីឆ្លើយតបទៅនឹងស្ថានភាពគ្រាប់បែកចង្កោមនៅ ក្នុង ប្រទេសកម្ពុជា។ វិធីសាស្ត្រនេះត្រូវបានបង្កើតឡើង សាកល្បង និងអនុវត្តនៅក្នុងប្រទេសកម្ពុជា ឡាវ និង វៀតណាម ដោយមានការកែសម្រួលតិចតួចឲ្យស្របទៅនឹងស្ថានភាពប្រទេសនីមួយៗ។

គោលបំណងនៃការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម គឺដើម្បីកំណត់រកទីតាំង គូសផែនទី និងកំណត់ តំបន់ដែលមានគ្រាប់បែកចង្កោម។ ការអនុវត្តការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម មានសារៈសំខាន់ សម្រាប់ ប្រទេសកម្ពុជា ដើម្បីប្រមូលព័ត៌មាន និងបោសសម្អាតចម្ការគ្រាប់បែកចង្កោមពិត ដោយប្រើប្រាស់ពេលវេលា សមស្រប និងធនធានតិចតួច។

បច្ចុប្បន្ននេះ នៅមិនទាន់មានស្តង់ដាអន្តរជាតិណាមួយ ចែងអំពីការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) ទេ ប៉ុន្តែមជ្ឈមណ្ឌលអន្តរជាតិសម្រាប់ការដោះមីនមនុស្សធម៌ទីក្រុងហ្សឺណែវ (GICHD) បានចេញ ផ្សាយឯកសារជាច្រើនដែលគ្របដណ្តប់លើប្រធានបទនេះ។ មុននឹងអានឯកសារស្តង់ដាកម្ចាត់មីនជំពូកទី ១៦នេះ អ្នកគួរអាន ឯកសារ "គោលការណ៍ណែនាំស្តីពីគ្រាប់បែកចង្កោម" ដែលចេញដោយ GICHD ក្នុងខែឧសភា ឆ្នាំ២០១៦ និងស្តង់ដាកម្ចាត់មីនកម្ពុជាជំពូក១៥ ស្តីពីការកាត់បន្ថយផ្ទៃដី ។

នៅក្នុងប្រទេសកម្ពុជា ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) មានភាពខុសគ្នាពីការស្រាវជ្រាវ មិន បច្ចេកទេស និងការស្រាវជ្រាវបច្ចេកទេស នៅលើតំបន់មានមីន ហើយការស្រាវជ្រាវនេះ ខុសគ្នាទៅនឹងការ ស្រាវជ្រាវគ្រាប់បែកចង្កោមដែលអនុវត្តក្នុងប្រទេសដទៃទៀតក្រៅតំបន់អាស៊ីអាគ្នេយ៍។

នៅក្នុងប្រទេសកម្ពុជា គ្រាប់បែកចង្កោម មិនមានកម្រិតគំរាមគំហែងដូចគ្រាប់មីនទេ ហើយគ្រាប់មីន ជាធម្មតាអាចផ្ទុះនៅពេលដែលរងទម្ងន់ពីមនុស្ស សត្វ ឬយានយន្ត។ ប៉ុន្តែគ្រាប់បែកចង្កោម ក៏អាចបង្កការ គំរាមកំហែងប្រសិនបើត្រូវទទួលរងកំដៅខ្លាំង(ឧទាហរណ៍ការដុត) ឬត្រូវបានវាយដំដោយវត្ថុរឹង ដូចជាចបកាប់ ឬ គ្រាប់បែកចង្កោមនោះត្រូវបានកែច្នៃដោយបុគ្គល ដែលមិនមានជំនាញ។ ចំពោះកុមារ គ្រាប់បែកចង្កោម អាចមាន ការគំរាមកំហែងខ្លាំងជាងគ្រាប់មីន។ គ្រាប់បែកចង្កោមមានរូបរាងតូច អាចមើលឃើញនៅលើផ្ទៃដី ដែលមានភាព ទាក់ទាញឲ្យកុមាររើសយកមកលេង។

នៅក្នុងក្របខណ្ឌប្រតិបត្តិការ ដោយការគំរាមគំហែងនៃគ្រាប់បែកចង្កោមនៅកម្ពុជាមានកម្រិតទាប ប្រតិបត្តិករអាច ពង្រាយកម្លាំងចូលក្នុងចម្ការគ្រាប់ដោយកម្រឹតនៃការប្រុងប្រយ័ត្នទាបជាងការដាក់ពង្រាយកម្លាំង នៅក្នុងចម្ការមីន។ ជាទូទៅមិនមានការរឹតត្បិតលើការបំលាស់ទីរបស់បុគ្គលិកក្នុងអំឡុងពេលស្រាវជ្រាវបច្ចេកទេស លើកលែងតែនៅពេលជីកកកាយរកប្រភពសម្លេង ឬការកម្ទេចគ្រាប់។ ដោយហេតុដូចនេះ ការដាក់ពង្រាយកម្លាំង ស្រាវជ្រាវសំណល់គ្រាប់បែកចង្កោមមានល្បឿនលឿនជាងការស្រាវជ្រាវបច្ចេកទេសនៅក្នុងចម្ការមីន។

## ១. ទំហំ និងវិសាលភាព

ស្តង់ដានេះ បង្កើតគោលការណ៍ និងផ្តល់ការណែនាំសម្រាប់ការរៀបចំបទដ្ឋានប្រតិបត្តិការ (SOPs) និងកំណត់ពីការទទួលខុសត្រូវ និងកាតព្វកិច្ចរបស់ប្រតិបត្តិករ និងភ្នាក់ងារបោសសម្អាតមីនទាំងអស់នៅប្រទេសកម្ពុជា ក្នុងការអនុវត្តការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម CMRS ដើម្បីរកឲ្យឃើញ និងកំណត់បាននូវចម្ការគ្រាប់បែកចង្កោមពិត CHA ដែលស្ថិតនៅក្នុងតំបន់សង្ស័យមានការគំរាមកំហែង (SHA)។

ពេលដែលគ្រាប់មីនប្រឆាំងមនុស្ស ឬមីនប្រឆាំងរថក្រោះ ត្រូវបានរកឃើញក្នុងអំឡុងពេលស្រាវជ្រាវ នោះការងារស្រាវជ្រាវ ត្រូវបញ្ឈប់ ហើយការស៊ើបអង្កេតត្រូវធ្វើឡើង។ ប្រសិនបើតំបន់នោះ អាចកំណត់ថាមិនមែនជាចម្ការមីន នោះប្រតិបត្តិការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) ត្រូវបន្ត។

## ២. វាក្យស័ព្ទ និងនិយមន័យ

សន្ទានុក្រមនៃវាក្យស័ព្ទ និយមន័យ និងពាក្យកាត់ទាំងអស់ ដែលបានប្រើនៅក្នុងស្តង់ដានេះ មានពន្យល់នៅក្នុងជំពូក៣០។

- តំបន់សង្ស័យមានការគំរាមកំហែង: ដីដែលគេសង្ស័យថាមានគ្រាប់បែកចង្កោម (យោងទៅតាមចំណាត់ចាត់ថ្នាក់ប្រភេទដីនៅក្នុងស្តង់ដាជំពូក១៤)
- ចម្ការគ្រាប់បែកចង្កោមពិត: ដីដែលមានគ្រាប់បែកចង្កោម។

## ៣. គោលការណ៍ទូទៅ

### គោលការណ៍នៃការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម(CMRS)

ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោមនៅក្នុងប្រទេសកម្ពុជា គឺជាការស្រាវជ្រាវផ្អែកលើភស្តុតាង ដែលចាប់ផ្តើមដោយការស្រាវជ្រាវមិនបច្ចេកទេស រួមជាមួយការសិក្សាទិន្នន័យដែលមានស្រាប់ ព្រមទាំងការប្រជុំភូមិ និងបន្តដោយការស្រាវជ្រាវបច្ចេកទេសលើតំបន់សង្ស័យមានការគំរាមគំហែងពីគ្រាប់បែកចង្កោម។

## ៤. ការស្រាវជ្រាវមិនបច្ចេកទេស

គោលបំណងនៃការស្រាវជ្រាវមិនបច្ចេកទេស (Non-Technical Survey) គឺបញ្ជាក់ពីភស្តុតាងនៃការគំរាមកំហែង ដើម្បីកំណត់ប្រភេទ កម្រិតនៃការគំរាមកំហែង និងឈានទៅកំណត់បាននូវទំហំនៃតំបន់សង្ស័យមានការគំរាមកំហែង។

ដំណើរការស្រាវជ្រាវមិនបច្ចេកទេស ចាប់ផ្តើមដោយការសិក្សា និងវិភាគលើប្រភេទទិន្នន័យមួយចំនួន ឧទាហរណ៍ដូចជា៖

ក) ទិន្នន័យទម្លាក់គ្រាប់បែករបស់សហរដ្ឋអាមេរិក
ខ) ទិន្នន័យស្រាវជ្រាវកន្លងមក
គ) ទិន្នន័យគ្រោះថ្នាក់មីន/គ្រាប់នៅក្នុងប្រព័ន្ធ CMVIS
ឃ) របាយការណ៍កម្ទេចគ្រាប់របស់ EOD កន្លងមក
ង) របាយការណ៍សហគមន៍

ច) ភស្តុតាងផ្សេងៗដែលបញ្ជាក់បានថាមានគ្រាប់បែកចង្កោម

ប្រសិនបើការសិក្សាលើទិន្នន័យដែលមានស្រាប់ បង្ហាញពីភស្តុតាងដែលអាចបញ្ជាក់បានថាមានគ្រាប់បែកចង្កោមនៅក្នុងតំបន់សង្ស័យមានការគំរាមកំហែង SHA ក្រុមស្រាវជ្រាវ ត្រូវរៀបចំកិច្ចប្រជុំជាមួយសហគមន៍ក្នុងគោលបំណងស្វែងរកប្រភពព័ត៌មាន ដែលអាចជឿទុកចិត្តបាន និងទៅត្រួតពិនិត្យទីតាំងជាក់លាក់ដើម្បីវិភាគបន្ថែមទៀត។ ភស្តុតាងមួយចំនួន ឧទាហរណ៍ដូចជា៖

ក) គ្រាប់បែកចង្កោមដែលមើលឃើញ

ខ)បំណែកគ្រាប់បែកចង្កោមដែលមើលឃើញ

គ) មេគ្រាប់បែកចង្កោមដែលមើលឃើញ

ឃ) សាក្សីដែលគួរឱ្យទុកចិត្តបានឃើញគ្រាប់បែកចង្កោម (យ៉ាងហោចណាស់មានអ្នកផ្តល់ព័ត៌មានច្បាស់ពីរនាក់)

ចំណុចភស្តុតាងដែលបានកត់ត្រាត្រូវចាត់ជាចំណុចចាប់ផ្តើមសម្រាប់ការស្រាវជ្រាវបច្ចេកទេស។

ត្រូវបញ្ចូលព័ត៌មានខាងក្រោមនៅក្នុងផែនទីស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS)៖

- ការគូសនិមិត្តសញ្ញាដូចបានកំណត់ក្នុងឧបសម្ព័ន្ធ ង នៃស្តង់ដាជំពូក១៥
- ចំណុចយោង (ចំណុចថេរ) ចំណុចយោងបន្ទាប់ ចំណុចចាប់ផ្តើម ចំណុចរបត់ និងចំណុចរបត់បន្ទាប់ ដែលអាចកំណត់បាន
- និយាមកា ចម្ងាយ និងទិសពីចំណុចយោងថេរ ចំណុចចាប់ផ្តើម និងចំណុចរបត់
- ទីតាំងគ្រាប់បែកចង្កោម/ERW និងដានគ្រាប់។

បន្ទាប់ពីការសិក្សាលើទិន្នន័យដែលមានស្រាប់ ជំហានទីពីរនៃការស្រាវជ្រាវមិនបច្ចេកទេសគឺត្រូវរៀបចំប្រជុំភូមិ ដើម្បីស្វែងរកភស្តុតាង ឬទីតាំង សំណល់គ្រាប់បែកចង្កោម ឬសំណល់ជាតិផ្ទុះពីសង្គ្រាម (ERW) ផ្សេងទៀត ដែលនឹងត្រូវកត់ត្រានៅក្នុងរបាយការណ៍តំបន់សង្ស័យមានការគំរាមកំហែង។

រាល់ចំណុចភស្តុតាងនៃគ្រាប់បែកចង្កោម ដែលបានកំណត់នៅក្នុងតំបន់សង្ស័យមានការគំរាមកំហែង នឹងក្លាយទៅជាចំណុចចាប់ផ្តើមសម្រាប់ការស្រាវជ្រាវបច្ចេកទេស។

គ្រាប់បែកចង្កោម ឬគ្រាប់មិនទាន់ផ្ទុះដទៃទៀត ដែលបានរកឃើញក្នុងដំណើរការស្រាវជ្រាវ នឹងត្រូវយកចេញ ឬកម្ទេចចោលក្នុងថ្ងៃតែមួយ ប្រសិនបើអាច។

## ៥. ការស្រាវជ្រាវបច្ចេកទេស

ការស្រាវជ្រាវបច្ចេកទេស សំដៅទៅលើការប្រមូល និងវិភាគទិន្នន័យទាក់ទងនឹងវត្តមានគ្រាប់បែកចង្កោម តាមរយៈប្រើប្រាស់បច្ចេកទេសសមស្របក្នុងការកំណត់តំបន់ដែលមាន ឬគ្មានគ្រាប់បែកចង្កោម ដើម្បីគាំទ្រដំណើរការរៀបចំផែនការ និងចាត់អាទិភាព។

ការស្រាវជ្រាវបច្ចេកទេសដែលត្រឹមត្រូវពេញលេញ ជួយឲ្យការបោសសម្អាតគ្រាប់បែកចង្កោមមានប្រសិទ្ធផល និងធ្វើឲ្យការរំដោះផ្ទៃដីប្រកបដោយទំនុកចិត្តដោយពុំចាំបាច់មានអន្តរាគមន៍បច្ចេកទេសបន្ថែមទៀត ហើយជាលទ្ធផលនាំឲ្យការប្រើប្រាស់ធនធានមានប្រសិទ្ធភាព។

ការទម្លាក់គ្រាប់បែកចង្កោមនីមួយៗបានបន្សល់ទុកដានដែលមានទ្រង់ទ្រាយ និងទំហំខុសៗគ្នា អាស្រ័យលើប្រភេទគ្រាប់ កម្ពស់ និងល្បឿននៅពេលដែលមេគ្រាប់ត្រូវបានទម្លាក់។ គោលបំណងនៃការស្រាវជ្រាវបច្ចេកទេស គឺកំណត់ព្រំនៃផ្ទៃដីដែលមានគ្រាប់បែកចង្កោម ដើម្បីជៀសវាងការចំណាយពេលវេលា និងធនធានលើការស្រាវជ្រាវនៅកណ្តាលនៃពហុកោណគ្រាប់ទម្លាក់ តាមដែលអាចធ្វើទៅបាន។ ទិន្នន័យទម្លាក់គ្រាប់របស់សហរដ្ឋអាមេរិក គោលដៅទម្លាក់គ្រាប់ ដាននៃទិសដៅហោះហើររបស់យន្តហោះ និងចំនុចភស្តុតាង គួរយកមកប្រើប្រាស់ដើម្បីជាជំនួយដល់ក្រុមស្រាវជ្រាវបច្ចេកទេស។

គោលបំណងចំបងនៃការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) គឺស្វែងរកភស្តុតាងនៃដានគ្រាប់ទម្លាក់។ ភស្តុតាងទាំងនោះ រួមមានគ្រាប់បែកចង្កោម គីប និងអំបែង។ ការស្រាវជ្រាវបច្ចេកទេស គួរធ្វើឲ្យបានរហ័សទៅលើផ្ទៃដីទំហំ ៥០ ម៉ែត្រ x ៥០ ម៉ែត្រ (២៥០០ ម៉ែត្រការ៉េ) នៅក្នុងទីតាំងប្រអប់ដែលចាប់ផ្តើមដំបូងជុំវិញចំណុចភស្តុតាង។ ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) គឺដើម្បីបញ្ជាក់ប្រអប់ណាដែលមានភស្តុតាងនៃវត្តមានសំណល់ជាតិផ្ទុះពីសង្គ្រាម។ បុគ្គលិកស្រាវជ្រាវចំនួនបួននាក់ដែលត្រួតពិនិត្យដោយមេក្រុមមួយនាក់ ត្រូវបានចាត់ឲ្យធ្វើការស្រាវជ្រាវនៅក្នុងប្រអប់នីមួយៗ។ នៅពេលបុគ្គលិកស្រាវជ្រាវម្នាក់រកឃើញគ្រាប់បែកចង្កោម ឬភស្តុតាងជាក់ស្តែង ដូចជាគីបគ្រាប់បែកចង្កោម ការស្រាវជ្រាវនៅក្នុងប្រអប់នោះនឹងត្រូវបញ្ចប់ ហើយប្រអប់នេះនឹងត្រូវផាត់ពណ៌ក្រហម ហើយភស្តុតាងក្នុងប្រអប់នឹងត្រូវកត់ត្រា។

ក្រុមស្រាវជ្រាវបច្ចេកទេសត្រូវប្រើប្រាស់ចំណុចភស្តុតាងជាចំណុចចាប់ផ្តើម សម្រាប់ការស្រាវជ្រាវ។ ការស្រាវជ្រាវនៅតំបន់ដែលមានព្រៃល្បាស់តិចទៅមធ្យមគួរប្រើគ្រីត (Grid) និងនីតិវិធីពុះប្រអប់។ មុនពេលដាក់ពង្រាយកម្លាំង ត្រូវបង្កើតផែនទីគ្រីត (Grid map) ១x១គីឡូម៉ែត្រដែលមាន៤០០ប្រអប់ ដែលប្រអប់នីមួយៗមានទំហំ៥០x៥០ម៉ែត្រ។ ផែនទីគ្រីត (Grid map) នេះនឹងត្រូវដាក់លើចំណុចភស្តុតាង ដែលមានស្រាប់ស្ថិតនៅជិតចំណុចកណ្តាល។ ការស្រាវជ្រាវបច្ចេកទេសជាធម្មតាចាប់ផ្តើមនៅក្នុងប្រអប់មួយ ដែលនៅជាប់នឹងភស្តុតាង ហើយឈានឆ្ពោះទៅរកដានគ្រាប់ទម្លាក់ក្នុងគោលបំណង ដើម្បីកំណត់ឲ្យបាននូវព្រំនៃដានគ្រាប់ទម្លាក់នោះ។

រាល់ចំណុចកណ្តាលនៃប្រអប់៥០x៥០ម៉ែត្រត្រូវដាក់បញ្ចូលក្នុងម៉ាស៊ីន GPS របស់ប្រធានក្រុម។ បន្ទាប់មក ប្រធានក្រុមត្រូវស្វែងរកចំណុចកណ្តាលនៃប្រអប់ដែលបានជ្រើសរើស ហើយប្រើប្រាស់ម៉ាស៊ីនរាវត្រួតពិនិត្យចំណុចកណ្តាលនោះមុនពេលដាំបង្គោលចូលក្នុងដី។ បុគ្គលិកស្រាវជ្រាវចំនួនបួននាក់រាយខ្សែរបស់គាត់ភ្ជាប់ទៅនឹងបង្គោល ហើយបែងចែកប្រអប់៥០x៥០ម៉ែត្រជាបួនផ្នែកដែលមានទំហំ២៥x២៥ម៉ែត្រ។ បុគ្គលិកស្រាវជ្រាវម្នាក់ៗត្រូវទទួលខុសត្រូវចំពោះការស្រាវជ្រាវប្រអប់របស់គាត់ ដែលមានការត្រួតពិនិត្យពីប្រធានក្រុមនៅក្នុងលំនាំដែលបានបង្ហាញខាងក្រោម។




**ឧទាហរណ៍នៃការពង្រាយកម្លាំងស្រាវជ្រាវនៅក្នុងប្រអប់៥០មx៥០ម**

ការពង្រាយកម្លាំងស្រាវជ្រាវនៅក្នុងប្រអប់ ៥០មx៥០ម ដែលត្រូវបានបែងចែកជាបួនប្រអប់តូច ២៥ម x២៥ម។ ប្រព័ន្ធនេះត្រូវការបុគ្គលិកស្រាវជ្រាវចំនួនបួននាក់ ដូចមានក្នុងឧទាហរណ៍ខាងលើ បុគ្គលិកម្នាក់ក្នុងចំណោមបុគ្គលិកទាំងបួននាក់មានតួនាទីអនុប្រធានក្រុម ។ ប្រធានក្រុមនឹងដឹកនាំបុគ្គលិកធ្វើការស្រាវជ្រាវក្នុងលំនាំមួយ ដែលធានានូវការមិនរំខានពីម៉ាស៊ីនរាវមីនមួយទៅម៉ាស៊ីនមួយទៀត។ ចំណុចខ្មៅទាំងបួនបង្ហាញពីចំណុចចាប់ផ្តើមរបស់បុគ្គលិកស្រាវជ្រាវម្នាក់ៗ និងមានការត្រួតពិនិត្យយ៉ាងជិតដល់ពីប្រធានក្រុម។ តាមធម្មតាការស្រាវជ្រាវនឹងត្រូវធ្វើឡើងនៅក្នុងទិសដៅពីជើងទៅត្បូង និងពីកើតទៅលិច។

ការស្រាវជ្រាវបច្ចេកទេសអាចត្រូវបានអនុវត្តជាសកម្មភាពឯករាជ្យ ឬអាចរួមបញ្ចូលជាមួយកិច្ចប្រតិបត្តិការបោសសម្អាត។ ប៉ុន្តែសូមរំលឹកថា មិនគួរប្រើប្រាស់ក្រុមស្រាវជ្រាវបច្ចេកទេសធ្វើការបោសសម្អាត មុនពេលចម្ការគ្រាប់ (SHA)ត្រូវបានកំណត់ជាចម្ការគ្រាប់បែកចង្កោមពិត (CHA)។ ធ្វើបែបនេះអាចឲ្យកម្ពុជារាយការណ៍បានត្រឹមត្រូវអំពីទំហំចម្ការគ្រាប់បែកចង្កោមពិតក្នុងពេលវេលាមួយដែលសមស្របៗក្នុងករណី ដែលភាគច្រើននៃចម្ការគ្រាប់នៅក្នុងតំបន់ត្រូវបានបញ្ចប់ការស្រាវជ្រាវបច្ចេកទេស ក្រុមស្រាវជ្រាវបច្ចេកទេស គួរដូរតួនាទីទៅជាក្រុមបោសសម្អាត ដើម្បីបោសសម្អាតចម្ការគ្រាប់បែកចង្កោមពិត យោងតាមដំណើរការរៀបចំផែនការ និងចាត់អាទិភាពនៅថ្នាក់ក្រោមជាតិ

## ប្រព័ន្ធឲ្យកូដពណ៌

អាស្រ័យលើលទ្ធផលនៃការស្រាវជ្រាវបច្ចេកទេស ប្រអប់នីមួយៗនឹងត្រូវដាក់ឲ្យមានពណ៌ដូចខាងក្រោម:

ការកំណត់ព័ណ៌ក្នុងប្រអប់ (៥០x៥០ម) នៅពេលដែលរកឃើញភស្តុតាង ក្នុងអំឡុងពេលធ្វើ CMRS

| COLOR CODE | IDENTIFICATION COLOUR | MEANING IN ENGLISH | MEANING IN KHMER | RGB CODE |
|---|---|---|---|---|
| **6** | Red ក្រហម | CM FOUND | រកឃើញគ្រាប់បែកចង្កោម | **255, 0, 0** |
| **5** | Yellow លឿង | CM FRAGMENT FOUND | រកឃើញអំបែងគ្រាប់បែកចង្កោម | **255, 255, 0** |
| **4** | Orange ទឹកក្រូច | ERW FOUND | រកឃើញគ្រាប់យុទ្ធភ័ណ្ឌមិនទាន់ផ្ទុះ | **255, 155, 55** |
| **3** | Blue ខៀវ | MK FOUND | រកឃើញគ្រាប់គ្រាប់ MK | **0, 155, 255** |
| **2** | Grey ប្រផេះ | INACCESSIBLE | មិនអាចចូលស្រាវជ្រាវបាន | **155, 155, 155** |
| **1** | Green បៃតង | NOTHING FOUND | រកមិនឃើញគ្រាប់ | **0, 255, 0** |
| **0** | White ស | NOT SURVEYD/SKIPPED | មិនទាន់បានចូលស្រាវជ្រាវ ឬរំលង | **255, 255, 255** |

របៀបដាក់ពណ៌ក្នុងប្រអប់នៃដំណើរការធ្វើ CMRS៖

ក) ចំណុចដែលបានរកឃើញគ្រាប់បែកចង្កោម ត្រូវបានដាក់ស្លាកសញ្ញាសម្គាល់ និងកត់ត្រាលេខនិយាមការ។ ប្រអប់នោះត្រូវបានលាបពណ៌ក្រហម (កូដពណ៌លេខ: ៦) នៅលើផែនទី (Grid Map) ហើយក្រុមត្រូវផ្លាស់ទីទៅប្រអប់បន្ទាប់ដើម្បីបន្តការស្រាវជ្រាវ។ គ្រាប់បែកចង្កោមដែលរកឃើញនឹងត្រូវកម្ទេចចោល។

ខ) ប្រសិនបើរកឃើញអំបែងដោយដឹងច្បាស់ថាជាផ្នែកមួយនៃគ្រាប់បែកចង្កោម ប្រអប់នោះនឹងត្រូវបានផាត់ពណ៌លឿង(កូដពណ៌លេខ: ៥) ហើយក្រុមត្រូវផ្លាស់ទីទៅប្រអប់បន្ទាប់ដើម្បីបន្តការស្រាវជ្រាវ។ អំបែងនឹងត្រូវយកចេញពីទីតាំងនោះ ដើម្បីជៀសវាងការរំខានដល់ក្រុមបោសសម្អាតនៅពេលក្រោយ។

គ) ចំណុចដែលបានរកឃើញសំណល់ជាតិផ្ទុះពីសង្គ្រាម (មិនមែនគ្រាប់បែកចង្កោម) នៅក្នុងប្រអប់ ត្រូវបានដាក់ស្លាកសញ្ញាសម្គាល់ និងកត់ត្រាលេខនិយាមការ។ ប្រអប់នោះមិនគួរផាត់ពណ៌ទឹកក្រូចនៅឡើយទេ (កូដពណ៌លេខ: ៤) ហើយក្រុមត្រូវបន្តស្រាវជ្រាវបន្ថែមទៀតរហូតដល់ពេញមួយប្រអប់ ប្រសិនបើរកឃើញគ្រាប់បែកចង្កោម ឬអំបែង ប្រអប់នោះនឹងត្រូវផាត់ពណ៌ក្រហម ឬពណ៌លឿង។ ប្រសិនបើរកមិនឃើញ ប្រអប់នោះនឹងត្រូវផាត់ពណ៌ទឹកក្រូច។ សំណល់ជាតិផ្ទុះពីសង្គ្រាម ERW នឹងត្រូវកម្ទេចចោល។

ឃ) ប្រសិនបើរកឃើញគ្រាប់ទម្លាក់ពីយន្តហោះ (MK) នៅក្នុងប្រអប់ គ្រាប់នោះនិងត្រូវបានដាក់ស្លាកសញ្ញាសម្គាល់ និងកត់ត្រាលេខនិយាមការ។ ប្រអប់នោះមិនគួរផាត់ពណ៌ទឹកខៀវនៅឡើយទេ (កូដពណ៌លេខ: ៣) ហើយក្រុមត្រូវបន្តស្រាវជ្រាវបន្ថែមទៀតរហូតដល់ពេញមួយប្រអប់ ប្រសិនបើរកឃើញគ្រាប់បែកចង្កោម ឬអំបែង ប្រអប់នោះនឹងត្រូវផាត់ពណ៌ក្រហម ឬពណ៌លឿង។ ប្រសិនបើរកមិនឃើញ ប្រអប់នោះនឹងត្រូវផាត់ពណ៌ខៀវ។ គ្រាប់ទម្លាក់ពីយន្តហោះ (MK) នឹងត្រូវយកចេញ ឬកម្ទេចចោលឲ្យបានត្រឹមត្រូវ។

ង) ប្រសិនបើប្រអប់ណាមួយមិនអាចចូលទៅដល់ ឬប្រធានក្រុមគិតថាប្រអប់នោះមានភាពលំបាកក្នុងការស្រាវជ្រាវតាមពេលវេលាដែលបានកំណត់ ប្រអប់នោះនឹងត្រូវផាត់ពណ៌ប្រផេះ (កូដពណ៌លេខ: ២) ហើយក្រុមត្រូវផ្លាស់ទីទៅប្រអប់បន្ទាប់ដើម្បីបន្តការស្រាវជ្រាវ។

ច) ប្រសិនបើរកមិនឃើញអ្វីនៅក្នុងប្រអប់តាមពេលវេលាដែលបានកំណត់ ប្រអប់នោះនឹងត្រូវផាត់ពណ៌បៃតង (កូដពណ៌លេខ: ១) ហើយក្រុមត្រូវផ្លាស់ទីទៅប្រអប់បន្ទាប់ដើម្បីបន្តការស្រាវជ្រាវ។

ឆ) ប្រអប់ណាមិនបានស្រាវជ្រាវ ប្រអប់នោះនៅរក្សាទុកជាពណ៌ស(កូដពណ៌លេខ: ០)។ ប្រសិនបើប្រអប់ណាមានពណ៌ស ក្នុងអំឡុងពេលនៃដំណើរការស្រាវជ្រាវ វាអាចមានន័យថាប្រអប់នោះអាចនឹងរង់ចាំការស្រាវជ្រាវ ប៉ុន្តែបើប្រអប់នោះនៅតែរក្សាទុកពណ៌សលើផែនទីចុងក្រោយ សន្មត់ថាប្រអប់ទាំងនោះត្រូវបានរំលង។

| | | | | | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| 20 | 40 | 60 | 80 | 100 | 120 | 140 | 160 | 180 | 200 | 220 | 240 | 260 | 280 | 300 | 320 | 340 | 360 | 380 | 400 |
| 19 | 39 | 59 | 79 | 99 | 119 | 139 | 159 | 179 | 199 | 219 | 239 | 259 | 279 | 299 | 319 | 339 | 359 | 379 | 399 |
| 18 | 38 | 58 | 78 | 98 | 118 | 138 | 158 | 178 | 198 | 218 | 238 | 258 | 278 | 298 | 318 | 338 | 358 | 378 | 398 |
| 17 | 37 | 57 | 77 | 97 | 117 | 137 | 157 | 177 | 197 | 217 | 237 | 257 | 277 | 297 | 317 | 337 | 357 | 377 | 397 |
| 16 | 36 | 56 | 76 | 96 | 116 | 136 | 156 | 176 | 196 | 216 | 236 | 256 | 276 | 296 | 316 | 336 | 356 | 376 | 396 |
| 15 | 35 | 55 | 75 | 95 | 115 | 135 | 155 | 175 | 195 | 215 | 235 | 255 | 275 | 295 | 315 | 335 | 355 | 375 | 395 |
| 14 | 34 | 54 | 74 | 94 | 114 | 134 | 154 | 174 | 194 | 214 | 234 | 254 | 274 | 294 | 314 | 334 | 354 | 374 | 394 |
| 13 | 33 | 53 | 73 | 93 | 113 | 133 | 153 | 173 | 193 | 213 | 233 | 253 | 273 | 293 | 313 | 333 | 353 | 373 | 393 |
| 12 | 32 | 52 | 72 | 92 | 112 | 132 | 152 | 172 | 192 | 212 | 232 | 252 | 272 | 292 | 312 | 332 | 352 | 372 | 392 |
| 11 | 31 | 51 | 71 | 91 | 111 | 131 | 151 | 171 | 191 | 211 | 231 | 251 | 271 | 291 | 311 | 331 | 351 | 371 | 391 |
| 10 | 30 | 50 | 70 | 90 | 110 | 130 | 150 | 170 | 190 | 210 | 230 | 250 | 270 | 290 | 310 | 330 | 350 | 370 | 390 |
| 9 | 29 | 49 | 69 | 89 | 109 | 129 | 149 | 169 | 189 | 209 | 229 | 249 | 269 | 289 | 309 | 329 | 349 | 369 | 389 |
| 8 | 28 | 48 | 68 | 88 | 108 | 128 | 148 | 168 | 188 | 208 | 228 | 248 | 268 | 288 | 308 | 328 | 348 | 368 | 388 |
| 7 | 27 | 47 | 67 | 87 | 107 | 127 | 147 | 167 | 187 | 207 | 227 | 247 | 267 | 287 | 307 | 327 | 347 | 367 | 387 |
| 6 | 26 | 46 | 66 | 86 | 106 | 126 | 146 | 166 | 186 | 206 | 226 | 246 | 266 | 286 | 306 | 326 | 346 | 366 | 386 |
| 5 | 25 | 45 | 65 | 85 | 105 | 125 | 145 | 165 | 185 | 205 | 225 | 245 | 265 | 285 | 305 | 325 | 345 | 365 | 385 |
| 4 | 24 | 44 | 64 | 84 | 104 | 124 | 144 | 164 | 184 | 204 | 224 | 244 | 264 | 284 | 304 | 324 | 344 | 364 | 384 |
| 3 | 23 | 43 | 63 | 83 | 103 | 123 | 143 | 163 | 183 | 203 | 223 | 243 | 263 | 283 | 303 | 323 | 343 | 363 | 383 |
| 2 | 22 | 42 | 62 | 82 | 102 | 122 | 142 | 162 | 182 | 202 | 222 | 242 | 262 | 282 | 302 | 322 | 342 | 362 | 382 |
| 1 | 21 | 41 | 61 | 81 | 101 | 121 | 141 | 161 | 181 | 201 | 221 | 241 | 261 | 281 | 301 | 321 | 341 | 361 | 381 |

ឧទាហរណ៍ខាងលើ បង្ហាញពីលទ្ធផលចុងក្រោយបន្ទាប់ពីការស្រាវជ្រាវបច្ចេកទេសត្រូវបានបញ្ចប់។ ដានគ្រាប់បែកចង្កោមត្រូវបានកំណត់យ៉ាងច្បាស់ ជាលទ្ធផល គ្រាប់បែកចង្កោមត្រូវបានរកឃើញនៅក្នុងប្រអប់ចំនួនប្រាំបួន(ពណ៌ក្រហម) មានប្រអប់បួនបន្ថែមដែលមានភស្តុតាងស្រាប់ សរុបប្រអប់ដែលបញ្ជាក់ពីភស្តុតាងមានចំនួន១៣។ លើសពីនេះ មានអំបែងគ្រាប់បែកចង្កោមដែលត្រូវបានរកឃើញនៅក្នុងប្រអប់ផ្សេងទៀតចំនួន ១៣ ដែលមានព័ណ៌លឿង។ ប្រអប់ពណ៌សមិនបានស្រាវជ្រាវ ហើយត្រូវបានរំលង ចំណែកឯប្រអប់ពណ៌បៃតង (រកមិនឃើញអ្វី) បង្ហាញពីតំបន់ដែលផុតពីការគំរាមកំហែង ហើយអាចជួយឲ្យក្រុមស្រាវជ្រាវក្នុងការកំណត់ព្រំប្រទល់ចម្ការគ្រាប់បែកចង្កោមពិត (CHA) ។

ពហុកោណចម្ការគ្រាប់បែកចង្កោមពិតត្រូវបោសសម្អាត គួរគូសនៅលើជាយខាងក្រៅនៃប្រអប់ពណ៌បៃតង ប៉ុន្តែគួរគិតគូអំពីការកាត់បន្ថយចំនួនរបត់មិនឲ្យមានភាពស្មុគស្មាញច្រើន។

នៅក្នុងតំបន់ព្រៃក្រាស់ ដែលមិនអាចដាក់ពង្រាយក្រុមស្រាវជ្រាវតាមលក្ខណៈបច្ចេកទេសនៃប្រព័ន្ធស្រាវជ្រាវតាមនីតិវិធីពុសប្រអប់។ ឧបករណ៍ ឬម៉ាស៊ីនកាត់ព្រៃអាចយកមកប្រើប្រាស់ ប៉ុន្តែជាទូទៅមិនគួរប្រើប្រាស់នោះទេ ព្រោះវិធីសាស្ត្រស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) គឺផ្តោតទៅលើល្បឿននៃការស្រាវជ្រាវឲ្យបានឆាប់រហ័សជាមួយនឹងការប្រើប្រាស់ធនធានជាអប្បបរមា។

ផ្ទុយទៅវិញក្រុមស្រាវជ្រាវគួរតែផ្តោតទៅលើតំបន់ជុំវិញតំបន់ព្រៃក្រាស់ ឬតំបន់មានឧបសគ្គផ្សេងៗដែលបង្អាក់ដល់ការពង្រាយកម្លាំងផ្ទាល់។ បន្ទាប់មកក្រុមនេះ ត្រូវប្រើប្រាស់ GPS ដើម្បីតាមដាន កត់ត្រាតំបន់ដែលបានស្រាវជ្រាវ។ ទិន្នន័យដែលបានកត់ត្រាដោយប្រព័ន្ធ GPS នេះ នឹងត្រូវដាក់នៅលើផែនទី (Grid Map) ហើយលេខនិយាមការនៃភស្តុតាងដែលបានរកឃើញក៏ត្រូវដាក់បញ្ចូលនៅលើផែនទី(Grid Map) ផងដែរ។ តំបន់ដែលត្រូវបានស្រាវជ្រាវនឹងគ្របដណ្តប់លើផ្នែកខ្លះនៃប្រអប់លើសពីមួយ លេខកូដពណ៌ក៏នៅតែអាចប្រើប្រាស់បាន។ ប្រព័ន្ធនេះនៅតែផ្តល់ការចង្អុលបង្ហាញយ៉ាងច្បាស់ដល់ក្រុមស្រាវជ្រាវក្នុងការកំណត់ចម្ការគ្រាប់បែកចង្កោមពិត CHA។

ការកំណត់ពេលវេលា និងភាគរយផ្ទៃដីដែលបានស្រាវជ្រាវគួរតែត្រូវបានកំណត់ និងបញ្ជាក់នៅក្នុងបទដ្ឋានប្រតិបត្តិការ (SOP) របស់ប្រតិបត្តិករ។ ការកំណត់ពេលវេលា និងភាគរយផ្ទៃដីដែលត្រូវស្រាវជ្រាវ អាស្រ័យលើស្ថានភាពដីផងដែរ ប៉ុន្តែប្រសិនបើរកមិនឃើញភស្តុតាងអ្វីទេ គួរតែមានការកំណត់ពេលវេលាសម្រាប់បញ្ឈប់ការស្រាវជ្រាវ និងផាត់ពណ៌បៃតងទៅលើប្រអប់នេះ ហើយបន្តទៅស្រាវជ្រាវប្រអប់បន្ទាប់។

ការរំលងប្រអប់គួរតែត្រូវបានអនុវត្ត ប្រសិនបើក្រុមស្រាវជ្រាវបានជួបប្រទះវត្តមានគ្រាប់បែកចង្កោម ប្រធានក្រុមត្រូវផាត់ពណ៌ក្រហមទៅលើប្រអប់នោះ ហើយមិនចាំបាច់ឲ្យក្រុមបន្តស្រាវជ្រាវនៅក្នុងប្រអប់ជាប់គ្នានោះទេ។ ផ្ទុយទៅវិញក្រុមស្រាវជ្រាវគួរតែរំលងប្រអប់មួយ ឬពីរ ដើម្បីបន្តការស្រាវជ្រាវប្រអប់ផ្សេងទៀត។ ជាទូទៅ ធ្វើបែបនេះ នឹងបង្កើនប្រសិទ្ធផលនៃការស្រាវជ្រាវ ក្នុងការពន្លឿនឆ្ពោះទៅដល់ចំណុចដែលជាព្រំប្រទល់នៃចម្ការគ្រាប់បែកចង្កោមពិត ហើយពុំចាំបាច់ចំណាយពេលច្រើនក្នុងការស្រាវជ្រាវនៅចំកណ្តាលនៃចម្ការគ្រាប់បែកចង្កោមពិត (CHA)។

## ៦. ធនធាន និងវិធីសាស្ត្រ

ជាទូទៅ ធនធាន និងវិធីសាស្ត្រ ត្រូវបានប្រើប្រាស់សម្រាប់ការស្រាវជ្រាវបច្ចេកទេស នៅក្នុងដំណើរការនៃការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម (CMRS) រួមមានៈ

ក) ការពង្រាយកម្លាំងមនុស្សដោយប្រើប្រាស់ម៉ាស៊ីនរាវមីន៖ បុគ្គលិកស្រាវជ្រាវអាចប្រើប្រាស់ម៉ាស៊ីនរាវមីនប្រភេទផ្សេងៗរាប់បញ្ចូលទាំងម៉ាស៊ីនរាវមីនជម្រៅជ្រៅ (large loops)។ ប្រតិបត្តិករនឹងត្រូវធ្វើតេស្តម៉ាស៊ីនដើម្បីបញ្ជាក់ថាម៉ាស៊ីននីមួយៗមានសមត្ថភាពក្នុងការស្វែងរកគ្រាប់នៅក្នុងជម្រៅដែលបានកំណត់ដោយស្តង់ដាជាតិ។ គំរូនៃប្រភេទគ្រាប់ដែលត្រូវស្វែងរកគួរតែត្រូវបានរៀបចំឲ្យមាននៅក្នុងការដ្ឋាន ដើម្បីប្រើប្រាស់ជាវត្ថុធ្វើតេស្ត។ ការធ្វើតេស្តម៉ាស៊ីនត្រូវធ្វើឲ្យបានជាប្រចាំ ហើយគួរធ្វើតេស្តបន្ថែមនៅពេលដែលមានការផ្លាស់ប្តូរប្រភេទដីគួរឱ្យកត់សម្គាល់។

ខ) សត្វហិតរកជាតិផ្ទុះ៖ ការប្រើប្រាស់សុនខហិតរកជាតិផ្ទុះ គឺជាមធ្យោបាយសមស្របសម្រាប់ការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម ក្នុងករណីភាគច្រើនសុនខហិតរកជាតិផ្ទុះមានប្រសិទ្ធភាពជាងការប្រើប្រាស់ម៉ាស៊ីនរាវមីន។ សុនខហិតរកជាតិផ្ទុះ (EDD) នឹងហិតរកតែជាតិផ្ទុះដោយមិនហិតរកលោហៈធាតុឡើយ ដូច្នេះនៅក្នុងតំបន់ដែលមានអំបែង និងដីមានជាតិដែកច្រើន សុនខនឹងក្លាយជាជម្រើសល្អបំផុត ប៉ុន្តែត្រូវមានបុគ្គលិកកាន់ម៉ាស៊ីនរាវផងដែរ។ ច្បាប់និងបទបញ្ញាទូទៅសម្រាប់សុនខហិតរកគ្រឿងផ្ទុះ ដែលត្រូវបានប្រើប្រាស់ក្នុងការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម នឹងនៅតែអនុវត្តប៉ុន្តែវិធីស្រាវជ្រាវនឹងមានការខុសគ្នាបន្តិចបន្តួច។

គ) គ្រឿងចក្រ៖ ជាទូទៅគ្រឿងចក្រ (គ្រឿងចក្របោសសម្អាត) មិនគួរត្រូវប្រើនៅក្នុងដំណើរការស្រាវជ្រាវសំណល់គ្រាប់បែកចង្កោមទេ (CMRS) ព្រោះវិធីសាស្ត្រស្រាវជ្រាវបច្ចេកទេស នៅក្នុងដំណើរការនេះ ផ្តោតទៅលើការពន្លឿនការពង្រាយកម្លាំង និងការស្រាវជ្រាវឲ្យបានលឿនបំផុតដោយប្រើប្រាស់ធនធានក្នុងកម្រិតអប្បបរមា។ នៅក្នុងស្ថានភាពខ្លះ ឧបករណ៍កាត់ព្រៃខ្នាតតូច និងម៉ាស៊ីនរៀបចំការដ្ឋានអាចប្រើប្រាស់បាន ប៉ុន្តែជាទូទៅមិនគួរប្រើប្រាស់ទេ។

ឃ) ការប្រើប្រាស់ធនធាន/ឧបករណ៍ស្រាវជ្រាវរួមគ្នា៖ ជាទូទៅការដាក់ពង្រាយអ្នកកាន់ម៉ាស៊ីនរាវ និងសុនខហិតរកជាតិផ្ទុះសម្រាប់ការស្រាវជ្រាវបច្ចេកទេសនៅក្នុងតំបន់គ្រាប់បែកចង្កោម គឺជាវិធីសាស្ត្រ ដ៏មានប្រសិទ្ធផលខ្ពស់។ ឧបករណ៍ផ្សេងទៀត ដូចជាដ្រូន (UAV) អាចប្រើប្រាស់បានសម្រាប់ជាជំនួយក្នុងការគូសផែនទី និងជួយដល់ការសម្រេចចិត្តក្នុងការពង្រាយកម្លាំង។

**ចំណាំ៖**

នៅពេលរកឃើញគ្រាប់មីនអំឡុងពេលស្រាវជ្រាវសំណល់គ្រាប់បែកចង្កោម ប្រតិបត្តិករត្រូវចាត់ទុកថាតំបន់នោះជាចម្ការមីន និងមិនមែនជាចម្ការគ្រាប់បែកចង្កោមទៀតទេ។ ការបន្តប្រើប្រាស់នីតិវិធីស្រាវជ្រាវបច្ចេកទេសគ្រាប់បែកចង្កោម នៅក្នុងតំបន់នេះ ត្រូវតែពិនិត្យឡើងវិញ។

## ៧. ការកំណត់ទំហំ និងរបាយការណ៍

ទំហំចម្ការគ្រាប់បែកចង្កោមពិតត្រូវបានកំណត់មិនឲ្យលើសពី២០ហិកតា ប្រសិនបើវាមានទំហំធំជាងការកំណត់ វាគួរតែត្រូវបានបំបែកទៅជាពហុកោណតូចសម្រាប់សកម្មភាពបន្ទាប់។ ប្រសិនបើមានព័ត៌មានគ្រប់គ្រាន់ ការបំបែកចម្ការគ្រាប់បែកចង្កោមពិតដែលមានទំហំធំលើសពីការកំណត់ វាគួរតែត្រូវបានចែកចេញជាផ្នែកតូច ដោយផ្អែកលើចំណុចភស្តុតាង និងស្ថានភាពភូមិសាស្ត្រជាក់ស្តែង។ បន្ទាប់ពីការស្រាវជ្រាវបច្ចេកទេសត្រូវបានបញ្ចប់ និងទំហំចម្ការគ្រាប់បែកចង្កោមពិតត្រូវបានកំណត់រួច ក្រុមស្រាវជ្រាវត្រូវបំពេញទម្រង់របាយការណ៍ស្រាវជ្រាវសំណល់គ្រាប់បែកចង្កោមហើយបញ្ជូនមកអង្គភាពទិន្នន័យរបស់អាជ្ញាធរមីន។

## ៨. ការទទួលខុសត្រូវនិងភាតព្វកិច្ច

### ៨.១ ការទទួលខុសត្រូវរបស់អាជ្ញាធរមីន

- ផ្តល់ប្រឹក្សាអំពីបទដ្ឋាននិងគោលការណ៍ណែនាំសម្រាប់ការធានាគុណភាព និងការត្រួតពិនិត្យគុណភាព ដែល ត្រូវអនុវត្តចំពោះកិច្ចសន្យា និងការចុះកិច្ចព្រមព្រៀងបោសសម្អាត។
- ផ្តល់បណ្ណ័ទទួលស្គាល់ និងអាជ្ញាបណ្ណ័ឱ្យដល់ប្រតិបត្តិករ
- ត្រួតពិនិត្យ និងកត់ត្រា សកម្មភាពស្រាវជ្រាវសំណល់គ្រាប់បែកចង្កោមរបស់ប្រតិបត្តិករ
- រក្សាកំណត់ត្រាផ្ទៃដីបានបោសសម្អាតរួច និងផ្ទៃដីមិនបានបោសសម្អាតដែលបង្ហាញពីស្ថានភាព ពហុកោណនីមួយៗនៃចម្ការគ្រាប់បែកចង្កោមពិត ឬតំបន់មានការសង្ស័យ។
- ត្រួតពិនិត្យអង្គការបោសសម្អាតមីន និងអង្គភាពចំណុះស្របតាមស្តង់ដាជំពូក៣ និងតម្រូវការនានានៃ កិច្ចសន្យា ឬកិច្ចព្រមព្រៀងបោសសម្អាតដែលពាក់ព័ន្ធ។
- រៀបចំឲ្យមាន និងទុកដាក់ឯកសារស្របច្បាប់ដែលពាក់ព័ន្ធនឹងការចុះទស្សនៈកិច្ច និងត្រួតពិនិត្យការដ្ឋាន។

### ៨.២ ការទទួលខុសត្រូវរបស់ប្រតិបត្តិករ

- ទទួលបានបណ្ណ័ទទួលស្គាល់ និងអាជ្ញាបណ្ណ័ពីអាជ្ញាធរមីន
- អនុវត្តការបោសសម្អាតតាមបទដ្ឋានប្រតិបត្តិការរបស់អង្គការ និងធានាបទដ្ឋានប្រតិបត្តិការរបស់សាមីស្ថាប័នស្របទៅនឹងស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា
- ប្រតិបត្តិករត្រូវបង្កើតបទដ្ឋានប្រតិបត្តិការសម្រាប់ការគូសពហុកោណចម្ការគ្រាប់បែកចង្កោមពិត CHA។
- រៀបចំ និងបញ្ជូនឯកសារនៃការបោសសម្អាតទៅតាមពេលវេលាដែលបានកំណត់ដោយអាជ្ញាធរមីន
- អនុវត្តការគ្រប់គ្រង និងនីតិវិធីប្រតិបត្តិការក្នុងគោលបំណងបោសសម្អាតផ្ទៃដីទៅតាមតម្រូវការ ដែលមានចែងក្នុងកិច្ចសន្យា ឬកិច្ចព្រមព្រៀងបោសសម្អាត។
- អនុវត្តនូវការធានាគុណភាព និងការត្រួតពិនិត្យគុណភាពផ្ទៃក្នុងស្របតាមបទដ្ឋានប្រតិបត្តិការ SOP។

### ៨.៣ ការទទួលខុសត្រូវរបស់ម្ចាស់ជំនួយ

- ទំនួលខុសត្រូវរបស់ភ្នាក់ងារម្ចាស់ជំនួយ គឺធានាថាគម្រោងដែលពួកគេបានផ្តល់មូលនិធិត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាព និងសុវត្ថិភាពដោយអនុលោមតាមស្តង់ដាសកម្មភាពកម្ចាត់មីនកម្ពុជា។

- ម្ចាស់ជំនួយត្រូវមានការទទួលខុសត្រូវផងដែរ ក្នុងការធានាថាភារកិច្ច និងគម្រោងដែលទទួលបានមូលនិធិ គឺស្របតាមអាទិភាពថ្នាក់ជាតិ និងថ្នាក់ខេត្ត តាមរយៈ អាជ្ញាធរមីន និងភីម៉ាក់/ម៉ាពូ។ ករណីនេះ ពាក់ព័ន្ធនឹងការយកចិត្តទុកដាក់យ៉ាងហ្មត់ចត់លើការកំណត់អត្តសញ្ញាណនៃគម្រោងបោសសម្អាត ការបង្កើតឯកសារកិច្ចព្រមព្រៀង និងការធានាថាប្រតិបត្តិករដែលត្រូវបានជ្រើសរើស សម្រាប់អនុវត្តកិច្ចព្រមព្រៀងនេះ ត្រូវស្របតាមលក្ខខណ្ឌបណ្ណ័ទទួលស្គាល់ អាជ្ញាបណ្ណ័ និងស្តង់ដារអាជ្ញាធរមីន។

ថ្ងៃចន្ទ ១២កើតខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែវិច្ឆិកា ឆ្នាំ ២០១៨

**អគ្គលេខាធិការ**

**ព្រំ សុគមង្គល**